# វប្បធម៌នយោបាយថ្មី

អ្នកចេះដឹងខ្មែរមួយចំនួន មានដើមគំនិត បង្កើតវប្បធម៌នយោបាយថ្មី ប្រហែលជានាំគ្នាយល់ឃើញថានៅស្រុកខ្មែរសព្វថ្ងៃ នយជន កំពុងប្រើវប្បធម៌នយោបាយមិនទាន់សម័យ និងគ្មានប្រសិទ្ធភាព។ វប្បធម៌ថ្មីនោះ បើធ្វើការសង្ខេប នូវ៦ចំណុចនៃគោលការណ៍ បានប្រកាសជាសាធារណ: គឺហាក់បីដូចជាការលាយចូលគ្នា រវាង វប្បធម៌សន្ទនា និង គោលការណ៍ មិនយកខ្មែរណាជាសត្រូវ នៅក្នុងដែនលទ្ធិប្រជាធិបតេយ្យ។ មានអ្នកខ្លះយល់ឃើញថាត្រូវមានដំណើរថ្មី គឺចុះទៅជួបប្រជារាស្ត្រ ដើម្បីប្រមូល នូវគំនិត ដែលគាត់ចង់បាន ដើម្បីអោយប្រជារាស្ត្រចូលរួមចំណែក ជាសកម្ម នៅក្នុងកិច្ចការ នយោបាយជាតិ។ គំនិតទាំងពីរនេះ វាមានទម្រង់ដូចជា លទ្ធិប្រជាធិបតេយ្យ ជាភាគកម្ម (démocratie participative) និង ពួកបាទចារី (les marcheurs) របស់លោកប្រធានាធិបតីបារាំង លោក Macron។ ការនាកម្ម (démarche) បែបនេះ វាហាក់បីដូចជា ពួកនោះធ្វើមិនដឹងថា រាស្ត្រខ្មែរ គាត់ចង់បានអ្វីពិតប្រាកដនៅឡើយ ដោយនាំគ្នា បំភ្លេច ជាចេតនាថា នៅស្រុកខ្មែរ បញ្ហា មិនមែនកើតមក ពីប្រជារាស្ត្រ មិនបានចូលរួមសកម្ម នៅក្នុងនយោបាយជាតិនោះឡើយ គឺអំណាចផ្តាច់ការទេ វាខាឃាំងមិនអោយប្រជារាស្ត្រ មានសេរីភាពពេញលេញ ជាពលរដ្ឋ។ ការនាកម្មនេះ គឺជាខ្យល់ថ្មី សំរាប់អំណាចផ្តាច់ការ បន្តរស់ ទេឬ: ? ចាស់ថាថ្មី ជាគ្រោះថ្នាក់ណាស់ សំរាប់ជាតិ៕

**ឧប សៅ សង្ហា** **គំនិត** **២៧ មិថុនា ២០១៨**